## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តបន្ទាយមានជ័យ**

- សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៣៩៥
 ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៣
- សាលក្រមព្រហ្មទណ្ឌលេខ៖ ៦៩ "ឈ"/ ៨៣២
 ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តបន្ទាយមានជ័យ

- បានបើកសវនាការជាសាធារណៈ នៅសាលសវនាការទី១ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ។
- កាលបរិច្ឆេទបើកសវនាការ ៖ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣។
- កាលបរិច្ឆេទប្រកាសសាលក្រម ៖ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣។

### ចៅក្រមជំនុំជម្រះ

- លោក [redacted] ជាចៅក្រមជំនុំជម្រះ

### តំណាងអយ្យការ

- លោក [redacted] ជាព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

- លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

**១.** ឈ្មោះ [redacted] **តុលា** ភេទប្រុស កើតឆ្នាំ១៩៩៤ ជានីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករ ទីកន្លែងកំណើត ខេត្តកំពង់ធំ អាសយដ្ឋានមុនពេលឃុំខ្លួនភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] មុំ "រស់" ម្តាយឈ្មោះ [redacted] អាន "រស់" ប្រពន្ធឈ្មោះ ហ៊ីង (លែងលះគ្នា) កម្រិតវប្បធម៌ (មិនចេះអក្សរ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

*ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៣៦ ព្រទ.ឃ"ជ"/២៣ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៣។*

ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា** និងបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅតាមបណ្តោយផ្លូវជាតិលេខ៥៨ ស្ថិតក្នុងភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២.** ឈ្មោ[redacted] **វណ្ណា:** ហៅ **ផេង** ភេទប្រុស កើតឆ្នាំ១៩៩១ ជានីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករ ទីកន្លែងកំណើតភូមិ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋាន



Scanned with CamScanner

បច្ចុប្បន្នភូ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] នឿន "រស់" ម្តាយឈ្មោះ[redacted]ធៀវ "រស់" នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី៥ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

*ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ លេខ ២២៥៥ ពស.ព្រស "ប"/២៣ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣។*

*មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ។*

៣. ឈ្មោះ [redacted] **ចិន** ហៅ **ចាន់** ភេទប្រុស អាយុ ៣២ឆ្នាំ ជានីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករ ទីកន្លែងកំណើតភូមិ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានបច្ចុប្បន្នភូមិ[redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] រាន "រស់" ម្តាយឈ្មោះ [redacted]អៀត "រស់" កម្រិតវប្បធម៌ថ្នាក់ទី៥ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

*ដីកាបង្គាប់ឱ្យដោះលែង លេខ ៩៩ ព្រទស"ជ"/២៣ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣។*

៤. ឈ្មោះ [redacted] **មិនា** ភេទប្រុស កើតឆ្នាំ១៩៩១ ជានីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរជាសន្តិសុខ ទីកន្លែងកំណើតភូមិ[redacted] ខេត្តកំពង់ធំ អាសយដ្ឋានបច្ចុប្បន្ននៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] អាន "រស់" ម្តាយឈ្មោះ [redacted] មុំ "រស់" កម្រិតវប្បធម៌ថ្នាក់ទី៣ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

*ដីកាបង្គាប់ឱ្យដោះលែង លេខ ៩៨ ព្រទស"ជ"/២៣ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣។*

ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅតាមបណ្តោយផ្លូវជាតិលេខ ៥៨ ស្ថិតនៅ ភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០២៣ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រដ្ឋា** ភេទស្រី អាយុ ៤៨ ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ អាសយដ្ឋានបច្ចុប្បន្នភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

*មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។*

### ១. អង្គហេតុចោទប្រកាន់មានដូចតទៅ

កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ មានករណី ធ្វើឱ្យខូចខាតដោយចេតនា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅតាមបណ្តោយផ្លូវជាតិលេខ៥៨ ស្ថិតក្នុងភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ មានជនសង្ស័យចំនួន ០៦នាក់ មានឈ្មោះ[redacted]អំ ភេទប្រុស អាយុ ៣២ឆ្នាំ, ឈ្មោះ [redacted] គ្រៀង ភេទប្រុស អាយុ ៣២ឆ្នាំ, ឈ្មោះ [redacted] ចិន ហៅចាន់ ភេទប្រុស អាយុ ៣២ឆ្នាំ, ឈ្មោះ [redacted] វណ្ណៈ ហៅ ផេង ភេទប្រុស អាយុ ៣២ឆ្នាំ, ឈ្មោះ [redacted] មិនា ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ[redacted] តុលា ភេទប្រុស អាយុ ២៩ឆ្នាំ បាននាំគ្នាអង្គុយផឹកស្រា ហើយបានយកដំពាមកៅស៊ូបាញ់ត្រូវរថយន្តម៉ាក ឡង់គ្រីស័រ GS-sport ពណ៌ខ្មៅ ផលិតឆ្នាំ២០២៣ បណ្តាលឱ្យបែកកញ្ចក់ទ្វារក្រោយផ្នែកខាងស្តាំ។ រថយន្តនោះជារបស់ជនរងគ្រោះឈ្មោះ [redacted] រដ្ឋា ភេទស្រី អាយុ ៤៨ឆ្នាំ។ ភ្លាមៗនោះជនរងគ្រោះបានឈប់រថយន្ត និងឃាត់ជនសង្ស័យទាំង ០៦ នាក់ និងបានរាយការណ៍ជូនកម្លាំងអាវុធហត្ថបានចុះល្បាតនៅក្នុងភូមិសាស្ត្រ និងបានឃាត់ខ្លួនជនសង្ស័យទាំង ០៦នាក់ខាងលើ និងបានដកហូតវត្ថុតាងជំពាមកៅស៊ូចំនួន ០១ដើម និងគ្រាប់ដែកចំនួន ០១ គ្រាប់ នាំយកមកកាន់កងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ដើម្បីចំណាត់ការតាមនីតិវិធី។ ឈ្មោះ [redacted] វណ្ណៈ ហៅ



Scanned with CamScanner

ផេង, ឈ្មោះ [redacted] ចិន ហៅ ចាន់, ឈ្មោះ [redacted] មិនា និងឈ្មោះ [redacted] តុលា ជាអ្នកប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤១៥ អ.យ.ខ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។
- បានឃើញ ដីកាដំណោះស្រាយលេខ ២៦៤៦ ពស.ព្រស-ជ-/២៣ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ។
- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៥១៤ ពស.ព្រជ "ក" / ២៣ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ។

## ២. នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] តុលា បានឆ្លើយថា អង្គហេតុដែលចោទប្រកាន់នេះមិនត្រឹមត្រូវទេ។ ចម្លើយនៅសមត្ថកិច្ច និងនៅតុលាការខ្លួនទទួលស្គាល់។ នៅថ្ងៃកើតហេតុខ្លួនបានទៅអង្គុយផឹកស្រាបៀរនៅផ្ទះឈ្មោះ [redacted] សុនី ជាមួយឈ្មោះ [redacted] វណ្ណៈ ហៅ ផេង, ឈ្មោះ [redacted] អំ, ឈ្មោះ [redacted] ព្រៀង និងឈ្មោះ [redacted] ចិន។ វេលាម៉ោងប្រហែល ១០យប់ មានឡានពណ៌ខ្មៅ មួយគ្រឿង បានមកឈប់នៅលើថ្នល់មុខផ្ទះឈ្មោះ [redacted] សុនី ហើយមកសួរពួកខ្លួនថា អ្នកណាគប់កញ្ចក់ឡានអញ ពួកខ្លួនបានប្រកែកថាមិនបានគប់ ពេលនោះឈ្មោះ [redacted] មីនា បានដើរមកដល់ ហើយម្ចាស់ឡានក៏ឃាត់គាត់មិនឱ្យទៅណា បន្ទាប់មកសមត្ថកិច្ចក៏មកឃាត់ខ្លួនតែម្តង។ ពេលទៅផឹកស៊ីខ្លួនបានយកជំពាមកៅស៊ូមួយ និងគ្រាប់ ០៣គ្រាប់ ថាយកទៅឱ្យប្អូន តែមិនទាន់បានឱ្យទេ ទាល់តែឈប់ផឹកទើបយកទៅឱ្យ។ គ្រាប់ចំនួន ០៣គ្រាប់ ខ្លួនបានដាក់លើកៅអីក្បែរខ្លួន ហើយវាបានជ្រុះរមៀលចូលក្រោមគ្រែក្បែរកន្លែងផឹក ខ្លួនមិនបានបាញ់ឡានគេទេ គ្រាប់ចំនួន ០១គ្រាប់ ដែលសមត្ថកិច្ចដកហូតនោះ រើសនៅជិតកន្លែងខ្លួនអង្គុយ តែមិនមែនរបស់ខ្លួនទេ គ្រាប់របស់ខ្លួនពណ៌ស តូចជាងគ្រាប់ដែលសមត្ថកិច្ចដកហូត។ ខ្លួនមិនបានប្រព្រឹត្តទេ តែជំពាមកៅស៊ូនោះពិតជារបស់ខ្លួនមែន។ ពេលឃាត់ខ្លួនគេបានដកហូតជំពាមកៅស៊ូ ចំនួន០១, ទូរស័ព្ទម៉ាក vivo មួយគ្រឿង, ជំពាមកៅស៊ូមួយ និងគ្រាប់មួយ។

- ជនជាប់ចោទឈ្មោះ [redacted] មិនា បានឆ្លើយថា ខ្លួនប្រើប្រាស់ថ្នាំញៀន ០៦ខែហើយ ប្រភេទម៉ាទឹកកក។ នៅថ្ងៃកើតហេតុ ខ្លួនដើរចេញពីផ្ទះទៅរកទិញអីហូប គ្រាន់តែខ្លួនដើរទៅដល់កន្លែងគេផឹក ស្រាប់តែគេចាប់ឃាត់ខ្លួនតែម្តង។ ពេលម្ចាស់ឡានគេចុះមកសួរ ខ្លួនមិនទាន់ដើរទៅដល់ទេ ហើយក៏មិនដឹងថា អ្នកណាជាអ្នកធ្វើដែរ ព្រោះខ្លួនទើបតែទៅដល់។

- ជនជាប់ចោទឈ្មោះ [redacted] ចិន បានឆ្លើយថា ខ្លួនបានប្រើប្រាស់ថ្នាំញៀន ០២ខែហើយ ប្រភេទម៉ាទឹកកក។ នៅថ្ងៃកើតហេតុមានតែឈ្មោះ [redacted] តុលា ម្នាក់ដែលមានជំពាមកៅស៊ូ ហើយពេលផឹកស៊ីឈ្មោះ [redacted] តុលា បានយកជំពាមកៅស៊ូ និងគ្រាប់ ០៣គ្រាប់ ដាក់នៅលើតុក្បែរខ្លួន ហើយពេលឈ្មោះ [redacted] តុលា ងើបដើរបានប៉ះតុ គ្រាប់ក៏រមៀលចូលក្រោមគ្រែម្ចាស់ផ្ទះ ដែលនៅចម្ងាយ ០១ម៉ែត្រ ពីកន្លែងពួកខ្លួនអង្គុយផឹក។ ពេលអង្គុយផឹកឈ្មោះ [redacted] តុលា មិនបានដើរទៅណាទេ ហើយពេលម្ចាស់ឡានចុះមកសួរនាំ ពួកខ្លួនពុំមានអ្នកណាសុំចេញទៅផ្ទះទេ។ ពេលឃើញម្ចាស់ឡានចុះមក មានតែឈ្មោះ [redacted] តុលា ម្នាក់ទេដែលមានការភ័យខ្លាចជាងគេ។ មុនពេលម្ចាស់ឡានចុះមកសួរនាំ ឈ្មោះ [redacted] វណ្ណៈ ហៅ ផេង បានដើរទៅនោម តែមិនមានកាន់អ្វីទេ កាន់តែទូរស័ព្ទ។

- តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា ខ្លួនប្រើប្រាស់ថ្នាំញៀនបានចំនួន ០២ ដង ដោយប្រើប្រាស់ប្រភេទម៉ាទឹកកក លើកចុងក្រោយនៅថ្ងៃទី



Scanned with CamScanner

០១ ខែឧសភា ឆ្នាំ២០២៣។ នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ ម៉ោង ៥ល្ងាច ខ្លួនបានទៅផឹកនៅផ្ទះរបស់ថៅកែ អស់ស្រាបៀកន្លះកេស រួចបន្តទៅផឹកផ្ទះរបស់ឈ្មោះ សុនី រហូតដល់ម៉ោង ៧ យប់ ឈ្មោះ សុនី ទៅដេកមុន ហើយខ្លួនបន្តចាក់បាស់ រួចមានឈ្មោះ [redacted] តុលា និងឈ្មោះ [redacted] ចិន ចូលមកផឹកជាមួយគ្នា ដោយឃើញឈ្មោះ [redacted] តុលា មានជំពាមកៅស៊ូ ប៉ុន្តែខ្លួនមិនដឹងថា ឈ្មោះ [redacted] តុលា បានបាញ់ឬអត់ទេ លុះដល់ម៉ោង ១០ យប់ ស្រាប់តែមានរថយន្តមួយគ្រឿង បានមកឈប់មុខផ្ទះដែលខ្លួនផឹកស៊ី ហើយចូលសួរថា អ្នកណាគប់កញ្ចក់ឡានគាត់បែក ពេលនោះពួកខ្លួនតបវិញថា មិនបានគប់ទេ និងមិនដឹងទេ រួចក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន។

- សាក្សីឈ្មោះ [redacted] អំ បានឆ្លើយថា នៅពេលខ្លួនទៅអង្គុយផឹក មិនឃើញមានឡានបើកកាត់មុខនោះទេ ហើយក៏មិនបានឃើញអ្នកគប់ ឬបាញ់កញ្ចក់ឡានគេដែរ។ ពេលម្ចាស់ឡានចុះមកសួរនាំ ចុះមកតែម្នាក់ឯងទេ ដោយដៃមានកាន់កាំភ្លើងមួយដើមមកផង ហើយសួរថា អ្នកណាគប់កញ្ចក់ឡាន នៅពេលនោះគ្មានអ្នកណាបានសុំទៅផ្ទះទេ។ នៅពេលខ្លួននៅផឹក គ្មានអ្នកណាទៅនោមទេ ព្រោះខ្លួនទើបតែទៅផឹកអស់កន្លះកំប៉ុងប៉ុណ្ណោះ។

- សាក្សីឈ្មោះ [redacted] ព្រៀង បានឆ្លើយថា ពេលម្ចាស់ឡានចុះមកសួរនាំ ពួកខ្លួននៅជុំគ្នា ឯម្ចាស់ផ្ទះឈ្មោះ ចៃវ៉ៃ គាត់ចូលក្នុងផ្ទះ ហើយខ្លួនមិនបានដឹងថា អ្នកណាសុំម្ចាស់ផ្ទះឈ្មោះ ចៃវ៉ៃ ទៅផ្ទះមុនទេ។

- តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] វិញ្ញាណ នៅដំណាក់កាលចៅក្រមស៊ើបសួរ បានឆ្លើយថា កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ២១ និង ៣០ ស្ថិតនៅបណ្តោយផ្លូវជាតិលេខ ៥៨ ស្ថិតនៅភូមិចំការគរ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ដោយមានជនសង្ស័យចំនួន ០៦ នាក់ មានឈ្មោះ [redacted] អំ ភេទប្រុស, ឈ្មោះ [redacted] ព្រៀង ភេទប្រុស, ឈ្មោះ [redacted] ចិន ហៅ ចាន់ ភេទប្រុស, ឈ្មោះ [redacted] វណ្ណៈ ភេទប្រុស, ឈ្មោះ [redacted] មីនា ភេទប្រុស និងឈ្មោះ [redacted] តុលា បាននាំគ្នាផឹកស៊ីនៅផ្ទះរបស់ឈ្មោះ [redacted] សុនី ភេទប្រុស រួចនៅក្នុងក្រុមនោះ មានជនសង្ស័យម្នាក់យកជំពាមកៅស៊ូបាញ់ទៅលើរថយន្តមួយគ្រឿងម៉ាក ឡង់គ្រីសស័រ GS Sport ពណ៌ខ្មៅ ផលិតឆ្នាំ២០២៣ ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] រដ្ឋា ភេទស្រី បណ្តាលឱ្យបែកកញ្ចក់ទ្វារ ខាងក្រោយផ្នែកខាងស្តាំ។ បន្ទាប់មកម្ចាស់រថយន្ត បានឃាត់ខ្លួនជនសង្ស័យទាំង ៦ នាក់ មកការិយាល័យព្រហ្មទណ្ឌកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ និងបានដកហូត ជំពាមកៅស៊ូខ្សែពណ៌លឿង ចំនួន ០១ និងគ្រាប់ឃ្លីដែកចំនួន ១ ពីឈ្មោះ [redacted] តុលា។

- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ធ្វើសេចក្តីសន្និដ្ឋានការពារ៖ ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិ ស្នើសុំលោកចៅក្រមជំនុំជម្រះ សម្រេចតាមច្បាប់។

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ៖ បន្ទាប់ពីឆ្លងកាត់ការសួរដេញដោលនាពេលសវនាការ តំណាងអយ្យការ យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] តុលា បានឆ្លើយបដិសេធថា ខ្លួនមិនបានគប់ ឬយកជំពាមកៅស៊ូបាញ់ទៅលើរថយន្តរបស់គេទេ តែជនជាប់ចោទបានឆ្លើយថា ពេលខ្លួនទៅផឹកខ្លួនបានយកជំពាមកៅស៊ូ និងគ្រាប់ចំនួន ០៣គ្រាប់ ដាក់តាមខ្លួន ហើយជំពាមកៅស៊ូដែលសមត្ថកិច្ចបានដកហូត គឺពិតជារបស់ខ្លួនមែន។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចិន បានឆ្លើយបញ្ជាក់ថា នៅពេលម្ចាស់ឡានចុះមកសួរនាំ ឃើញឈ្មោះ [redacted] តុលា មានការភ័យខ្លាចជាងគេ។ ជនជាប់ចោទឈ្មោះ [redacted] ចិន, ឈ្មោះ [redacted] មិនា និងឈ្មោះ [redacted] វណ្ណៈ បានឆ្លើយសារភាពថា ពួកខ្លួនពិតជាបានប្រើប្រាស់គ្រឿងញៀនប្រាកដមែន។ ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ និងភស្តុតាងផ្សេងៗក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] តុលា ពិតជាបានប្រព្រឹត្តអំពើ ធ្វើឱ្យខូចខាតដោយចេតនា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥



Scanned with CamScanner

នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ដូច្នេះតំណាងអយ្យការរក្សាបទចោទប្រកាន់ដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

- លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ធ្វើសេចក្តីសន្និដ្ឋានការពារៈ បន្ទាប់ពីឆ្លងកាត់ការសួរដេញដោលនាពេលសវនាការ ឃើញថា កូនក្តីខ្ញុំបាទឈ្មោះ [redacted] វណ្ណៈ ពិតជាបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ប៉ុន្តែក្រោយពីកូនក្តីខ្ញុំបាទត្រឡប់ទៅផ្ទះវិញ កូនក្តីខ្ញុំមានការកែប្រែខ្លួន ពុំបានប្រើប្រាស់នូវសារធាតុញៀនទៀតទេ។ ក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិ ខ្ញុំសំណូមពរលោកចៅក្រមជំនុំជម្រះ មេត្តាពិនិត្យពិចារណា និងសម្រេចឱ្យកូនក្តីខ្ញុំបាទ រួចផុតពីបទចោទខាងលើ ដោយហេតុថា ក្រោយពីកូនក្តីខ្ញុំត្រូវបានតុលាការសម្រេចដោះលែងមក គាត់បានកែប្រែខ្លួន និងពុំបានប្រើប្រាស់ថ្នាំញៀនទៀតទេ។

- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] តុលា៖ សុំឱ្យតុលាការរកយុត្តិធម៌ឱ្យខ្លួនផង។
- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ចិន៖ សុំឱ្យតុលាការរកយុត្តិធម៌ឱ្យខ្លួនផង។
- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] មិនា៖ គ្មាន។

## តុលាការ

- ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹង
- ក្រោយពីបានស្តាប់ចម្លើយ និងអំណានរបស់សាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានានៅក្នុងសំណុំរឿង។

## ៣. សំអាងហេតុ

១. តាមដីកាបញ្ជូនទៅជំនុំជម្រះលេខ ២៦៤៦ ពស.ព្រស-ដ-/២៣ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០២៣ ចៅក្រមស៊ើបសួរបានប្តឹងចោទប្រកាន់ជនជាប់ចោទ៖

- ឈ្មោះ [redacted] តុលា ហៅ ខ្លឹង ភេទប្រុស កើតឆ្នាំ១៩៩៤ ពីបទ ធ្វើឱ្យខូចខាតដោយចេតនា និងបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅតាមបណ្តោយផ្លូវជាតិលេខ៥៨ ស្ថិតនៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- ឈ្មោះ [redacted] វណ្ណៈ ហៅ ផេង ភេទប្រុស អាយុ ៣២ឆ្នាំ, ឈ្មោះ [redacted] ចិន ហៅ ចាន់ ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ [redacted] មិនា ភេទប្រុស កើតឆ្នាំ១៩៩១ ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅតាមបណ្តោយផ្លូវជាតិលេខ ៥៨ ស្ថិតនៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

២. ជនជាប់ចោទឈ្មោះ [redacted] តុលា ភេទប្រុស៖

- តាមចម្លើយរបស់ជនជាប់ចោទបានឆ្លើយនាពេលសវនាការថា នៅថ្ងៃកើតហេតុខ្លួនបានទៅអង្គុយផឹកស្រាបៀរនៅផ្ទះឈ្មោះ [redacted] សូនី ជាមួយឈ្មោះ [redacted] វណ្ណៈ ហៅ ផេង, ឈ្មោះ [redacted] អំ, ឈ្មោះ [redacted] ព្រៀង និងឈ្មោះ [redacted] ចិន។ វេលាម៉ោងប្រហែល ១០យប់ មានឡានពណ៌ខ្មៅ មួយគ្រឿង បានមកឈប់នៅលើថ្នល់មុខផ្ទះឈ្មោះ [redacted] សូនី ហើយមកសួរពួកខ្លួនថា អ្នកណាគប់កញ្ចក់ឡានអញ ពួកខ្លួនបានប្រកែកថាមិនបានគប់ ពេលនោះឈ្មោះ [redacted] មីនា បានដើរមកដល់ ហើយម្ចាស់ឡានក៏ឃាត់គាត់មិនឱ្យទៅណា បន្ទាប់មកសមត្ថកិច្ចក៏មកឃាត់ខ្លួនតែម្តង។ ពេលទៅផឹកស៊ីខ្លួនបានយកជំពាមកៅស៊ូមួយ និងគ្រាប់ ០៣គ្រាប់ ថាយកទៅឱ្យប្អូន តែមិនទាន់បានឱ្យទេ ទាល់តែឈប់ផឹកទើបយកទៅឱ្យ។ គ្រាប់ចំនួន ០៣គ្រាប់ ខ្លួនបានដាក់លើកៅអីក្បែរខ្លួន ហើយវាបានជ្រុះរមៀលចូលក្រោមគ្រែក្បែរកន្លែងផឹក ខ្លួនមិនបានបាញ់ឡានគេទេ គ្រាប់ចំនួន ០១គ្រាប់ ដែលសមត្ថកិច្ចដកហូតនោះ រើសនៅជិតកន្លែងខ្លួនអង្គុយ តែមិនមែនរបស់ខ្លួនទេ គ្រាប់របស់ខ្លួនពណ៌ស តូចជាងគ្រាប់ដែលសមត្ថកិច្ចដកហូត។ ខ្លួនមិនបានប្រព្រឹត្តទេ តែជំពាមកៅស៊ូនោះពិតជារបស់ខ្លួនមែន។

- តាមចម្លើយបដិសេធរបស់ជនជាប់ចោទគ្រប់ដំណាក់កាល មិនអាចឱ្យតុលាការជឿជាក់បានទេ ដោយហេតុថា នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ១០ យប់ ជនជាប់ចោទពិតជាបានយកជំពាមកៅស៊ូចំនួន ០១ និងគ្រាប់ចំនួន ៣ គ្រាប់ដាក់តាមខ្លួនពិតមែន ទោះបីជាជនជាប់ចោទបានឆ្លើយបដិសេធថា ខ្លួនមិនបានបាញ់ជំពាមកៅស៊ូ ហើយក៏មិនបានចេញក្រៅដែល ប៉ុន្តែពេលសមត្ថកិច្ចឃាត់ខ្លួន និងឆែកឆេរនៅកន្លែងក្រុមជនជាប់ចោទអង្គុយផឹកស៊ី មិនឃើញមានគ្រាប់ជំពាមចំនួន ០៣ គ្រាប់ ដែលជនជាប់ចោទបានអះអាងឡើយ ផ្ទុយទៅវិញគឺឆែកឃើញតែគ្រាប់ចំនួន ០១ គ្រាប់ ប៉ុណ្ណោះ។ ចំពោះការបដិសេធរបស់ជនជាប់ចោទ ដែលបានឆ្លើយថា គ្រាប់ជំពាម ដែលសមត្ថកិច្ចបានដកហូត មិនមែនជារបស់ខ្លួន ប៉ុន្តែជនជាប់ចោទមិនបានបង្ហាញដល់សមត្ថកិច្ច នូវគ្រាប់ដែលខ្លួនបានអះអាងថា ជារបស់ខ្លួនមានចំនួន ០៣ គ្រាប់ឡើយ ដូច្នេះចម្លើយបដិសេធនេះ មិនអាចឱ្យតុលាការជឿជាក់បានឡើយ។

- ផ្អែកតាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ចិន បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា ពេលម្ចាស់រថយន្តម៉ាកឡង់គ្រីសស័រ ពណ៌ខ្មៅ ចុះមកស្រែកសួរពួកខ្លួនថា អ្នកណាគប់កញ្ចក់ឡានគាត់ ភ្លាមនោះខ្លួនឃើញទឹកមុខរបស់ឈ្មោះ [redacted] តុលា ប្រែពណ៌ខ្មៅ មានសភាពភ័យ ចំណែកជំពាមកៅស៊ូខ្សែពណ៌លឿង ដែលជារបស់ តុលា ដែលទុកគៀនខ្លួនវា វាបានគៀសចេញឆ្ងាយពីខ្លួន ហើយឈ្មោះ តុលា បានប្រាប់ថៃវ៉ៃ ទៅផ្ទះមុន តែម្ចាស់រថយន្តមិនឱ្យទៅណា។ ផ្អែកតាមចម្លើយនេះបង្ហាញថា ឈ្មោះ [redacted] តុលា បានដឹងខ្លួន មានចេតនាគេចវេស និងគេចខ្លួនចេញពីកន្លែងកើតហេតុ។

- ម៉្យាងវិញទៀត ពេលសមត្ថកិច្ចចុះដល់ទីតាំងកើតហេតុ មិនមានអ្នកផ្សេងដែលនៅកន្លែងកើតហេតុឡើង។ ផ្អែកតាមសំអាងហេតុខាងលើបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] តុលា ពិតជាបានបាញ់ជំពាមកៅស៊ូ ដែលបណ្តាលឱ្យបែកកញ្ចក់រថយន្តម៉ាក ឡង់គ្រីស័រ ខាងក្រោយផ្នែកខាងស្តាំប្រាកដមែន។

- ផ្អែកតាមកស្តុតាងជារូបភាព *(ឯកសារលេខ ០១/៨៦ និង ០១/៨៧)* បង្ហាញថា រថយន្តម៉ាកឡង់គ្រីស័រ ពណ៌ខ្មៅ ពិតជាបែកកញ្ចក់ខាងក្រោយ ផ្នែកស្តាំប្រាកដមែន។

- តាមកំណត់ហេតុធ្វើតេស្តទឹកនោម ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃមន្ទីរស្រាវជ្រាវ និងបង្ក្រាបបទល្មើស នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយ-មានជ័យ បង្ហាញថា ឈ្មោះ [redacted] តុលា *"មានវិជ្ជមាននូវសារធាតុញៀន"*។



Scanned with CamScanner

- តាមចម្លើយរបស់ជនជាប់ចោទ និងភស្តុតាងនានាក្នុងសំណុំរឿង បញ្ជាក់បានថា កាលពីថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០២៣ ឈ្មោះ [redacted] តុលា ភេទប្រុស ពិតជាបានយកដំបងកៅស៊ូបាញ់ នៅតាមបណ្តោយផ្លូវជាតិលេខ៥៨ ស្ថិតនៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ បណ្តាលឱ្យបែកកញ្ចក់ រថយន្តម៉ាក ឡង់គ្រីស័រ ខាងក្រោយផ្នែកខាងស្តាំ ជារបស់ឈ្មោះ [redacted] វង្សា ភេទស្រី ប្រាកដមែន។ អំពើនេះត្រូវបានច្បាប់កំណត់ថា ជាបទ ធ្វើឱ្យខូចខាតដោយចេតនា និងបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ *ពីបទ ធ្វើឱ្យខូចខាតដោយចេតនា និងបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន* ប្រព្រឹត្តនៅតាមបណ្តោយផ្លូវជាតិលេខ ៥៨ ស្ថិតនៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ គប្បីតុលាការប្រកាសពី ពិរុទ្ធភាព និងប្រកាសទោសលើជនជាប់ចោទ តាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣. ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ហៅ ផេង ភេទប្រុស, ឈ្មោះ [redacted] ចិន ហៅ ចាន់ ភេទប្រុស និងឈ្មោះ [redacted] មិនា ភេទប្រុស៖

- ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់-កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ ប្រហាក់ប្រហែលគ្នាថា ខ្លួនប្រើប្រាស់ថ្នាំញៀនបានចំនួន ០២ ដង ដោយប្រើប្រាស់ប្រភេទម៉ាទឹកកក លើកចុងក្រោយនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៣។

- ជនជាប់ចោទឈ្មោះ [redacted] ចិន បានឆ្លើយសារភាពនាពេលសវនាការថា ខ្លួនបានប្រើប្រាស់ថ្នាំញៀន ០២ខែហើយ ប្រភេទម៉ាទឹកកក។

- ជនជាប់ចោទឈ្មោះ [redacted] មិនា បានឆ្លើយសារភាពនាពេលសវនាការថា ខ្លួនប្រើប្រាស់ថ្នាំញៀន ០៦ខែហើយ ប្រភេទម៉ាទឹកកក។

- តាមកំណត់ហេតុធ្វើតេស្តទឹកនោម ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃមន្ទីរស្រាវជ្រាវ និងបង្ក្រាបបទល្មើស នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ បង្ហាញថា ឈ្មោះ [redacted] វណ្ណៈ, ឈ្មោះ [redacted] ចិន និងឈ្មោះ [redacted] មិនា មានវិជ្ជមាននូវសារធាតុញៀន។

- តាមចម្លើយសារភាពរបស់ជនជាប់ចោទ និងភស្តុតាងនានាក្នុងសំណុំរឿង បញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] មិនា ភេទប្រុស, ឈ្មោះ [redacted] ចិន ហៅ ចាន់ ភេទប្រុស និងឈ្មោះ [redacted] វណ្ណៈ ហៅ ផេង ភេទប្រុស ពិតជាបានប្រើប្រាស់ថ្នាំញៀនប្រាកដមែន។ អំពើរបស់ជនជាប់ចោទ ត្រូវបានកំណត់ថា ជាបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] មិនា ភេទប្រុស, ឈ្មោះ [redacted] ចិន ហៅ ចាន់ ភេទប្រុស និងឈ្មោះ [redacted] វណ្ណៈ ហៅ ផេង ភេទប្រុស ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅតាមបណ្តោយផ្លូវជាតិលេខ ៥៨ ស្ថិតនៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយ-ចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ គប្បីតុលាការប្រកាសពីពិរុទ្ធភាព និងប្រកាសទោសលើជនជាប់ចោទ តាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

៤. ជនជាប់ចោទស្ថិតនៅក្នុងវ័យដែលតុលាការអាចធ្វើការប្រកាសទោសព្រហ្មទណ្ឌបាន ហើយមិនមានសញ្ញាណណាមួយបញ្ជាក់បានថា ជនជាប់ចោទមានវិបត្តិខាងបញ្ញាស្មារតីឡើយ។

៥. លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ធ្វើសេចក្តីសន្និដ្ឋានការពារ ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិ ស្នើសុំលោកចៅក្រមជំនុំជម្រះ សម្រេចតាមច្បាប់។

៦. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ បន្ទាប់ពីឆ្លងកាត់ការសួរដេញដោលនាពេលសវនាការ តំណាងអយ្យការ យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] តុលា បានឆ្លើយបដិសេធថា ខ្លួនមិនបានគប់ ឬយកដំពាមកៅស៊ូបាញ់ទៅលើរថយន្តរបស់គេទេ តែជនជាប់ចោទបានឆ្លើយថា ពេលខ្លួនទៅជិះខ្លួនបានយកដំពាមកៅស៊ូ និងគ្រាប់ចំនួន ០៣ គ្រាប់ ដាក់តាមខ្លួន ហើយដំពាមកៅស៊ូដែលសមត្ថកិច្ចបានដកហូត គឺពិតជារបស់ខ្លួនមែន។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចិន បានឆ្លើយបញ្ជាក់ថា នៅពេលម្ចាស់ឡានចុះមកសួរនាំ ឃើញឈ្មោះ [redacted] តុលា មានការភ័យខ្លាចជាងគេ។ ជនជាប់ចោទឈ្មោះ [redacted] ចិន, ឈ្មោះ [redacted] មិនា និងឈ្មោះ [redacted] វណ្ណៈ បានឆ្លើយសារភាពថា ពួកខ្លួនពិតជាបានប្រើប្រាស់គ្រឿងញៀនប្រាកដមែន។ ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ និងកស្តុតាងផ្សេងៗក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] តុលា ពិតជាបានប្រព្រឹត្តអំពើ ធ្វើឱ្យខូចខាតដោយចេតនា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ដូច្នេះតំណាងអយ្យការ រក្សាបទចោទប្រកាន់ដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ គប្បីតុលាការលើកមកពិចារណា។

៧. មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ធ្វើសេចក្តីសន្និដ្ឋានការពារ៖ បន្ទាប់ពីឆ្លងកាត់ការសួរដេញដោលនាពេលសវនាការ ឃើញថា កូនក្តីខ្ញុំបាទឈ្មោះ [redacted] វណ្ណៈ ពិតជាបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ប៉ុន្តែក្រោយពីកូនក្តីខ្ញុំបាទត្រឡប់ទៅផ្ទះវិញ កូនក្តីខ្ញុំមានការកែប្រែខ្លួន ពុំបានប្រើប្រាស់នូវសារធាតុញៀនទៀតទេ។ ក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិ ខ្ញុំសំណូមពរលោកចៅក្រមជំនុំជម្រះ មេត្តាពិនិត្យពិចារណា និងសម្រេចឱ្យកូនក្តីខ្ញុំបាទ រួចផុតពីបទចោទខាងលើ ដោយហេតុថា ក្រោយពីកូនក្តីខ្ញុំត្រូវបានតុលាការសម្រេចដោះលែងមក គាត់បានកែប្រែខ្លួន និងពុំបានប្រើប្រាស់ថ្នាំញៀនទៀតទេ។

៨. ជនជាប់ចោទឈ្មោះ [redacted] តុលា ភេទប្រុស និងឈ្មោះ [redacted] ចិន ភេទប្រុស បានថ្លែងសេចក្តីចុងក្រោយ សុំឱ្យតុលាការរកយុត្តិធម៌ឱ្យខ្លួនផង។ ចំណែកជនជាប់ចោទឈ្មោះ [redacted] មិនា ភេទប្រុស មិនមានសំណូមពរ។ តុលាការនឹងលើកមកពិចារណា។

៩. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រដ្ឋា ភេទស្រី ដោយមានលោក មេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ បានថ្លែងនៅដំណាក់កាលចៅក្រមស៊ើបសួរ និងនាពេលសវនាការថា ក្នុងនាមអ្នកតំណាងដោយអាណត្តិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ខ្លួនមិនទាមទាសំណងជម្ងឺចិត្តឡើយ ស្នើសុំតុលាការផ្តន្ទាទោសតាមច្បាប់។ តុលាការនឹងលើកមកពិចារណា។

១០. តាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១៥៤ អ.យ.ខ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៣ បានទទួលវត្ថុតាងមាន៖

- ដំពាមកៅស៊ូ ចំនួន ០១។
- នាឡិកាដៃ ចំនួន ០២គ្រឿង។
- កាស Bluetooth (apple) ចំនួន ០១។
- គ្រាប់ឃ្លីដែក ចំនួន ០១គ្រាប់ ដាក់ក្នុងដបទឹកសុទ្ធ។



Scanned with CamScanner

- ទូរស័ព្ទ ចំនួន ០២គ្រឿង ម៉ាក Vivo v2026 ពណ៌ខ្មៅ IMEI1: 865091059208176 និងម៉ាក Vivo 1906 ពណ៌ខ្មៅលាយក្រហម IMEI1: 864809045390654។

*"វត្ថុតាងចាប់យកជា ជំពាមកៅស៊ូ ចំនួន ០១ និងគ្រាប់ឃ្លីដែកចំនួន ០១ គ្រាប់ ត្រូវបានជនជាប់ចោទយកមកប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស គប្បីធ្វើការរឹបអូស តាមបញ្ញត្តិមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។ ចំណែកវត្ថុចាប់យកផ្សេង ឃើញថា មិនបានពាក់ព័ន្ធនឹងបទល្មើសឡើយ គប្បីប្រគល់ឱ្យទៅម្ចាស់ដើមវិញ។"*

**៤. ហេតុដូច្នេះ សម្រេច**

**១. ផ្តន្ទាទោស**

**១.១.** ឈ្មោះ [redacted] **តុលា** ភេទប្រុស កើតឆ្នាំ១៩៩៤ ជានីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករ ទីកន្លែងកំណើត ខេត្តកំពង់ធំ អាសយដ្ឋានមុនពេលឃុំខ្លួនភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] មុំ "រស់" ម្តាយឈ្មោះ [redacted] អាន "រស់" ប្រពន្ធឈ្មោះ ហ៊ីង (លែងលះគ្នា) កម្រិតវប្បធម៌ (មិនចេះអក្សរ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ *(ក្នុងឃុំ)*

**កំណត់ដាក់ពន្ធនាគាររយៈពេល ១០ (ដប់) ខែ** ពីបទ **ធ្វើឱ្យខូចខាតដោយចេតនា** និងបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**១.២.** ឈ្មោះ [redacted] **វណ្ណា** ហៅ **ផេង** ភេទប្រុស កើតឆ្នាំ១៩៩១ ជានីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករ ទីកន្លែងកំណើតភូមិ[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានបច្ចុប្បន្នភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] នឿន "រស់" ម្តាយឈ្មោះ [redacted] ធៀវ "រស់" នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី ៥ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

**កំណត់ដាក់ពន្ធនាគាររយៈពេល ៤ (បួន) ខែ តែទោសនេះអនុវត្តក្នុងពន្ធនាគារពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ទោសនៅសល់ព្យួរធម្មតា** តាមបញ្ញត្តិមាត្រា ១០៤ ដល់មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**១.៣.** ឈ្មោះ [redacted] **ចិន** ហៅ **ចាន់** ភេទប្រុស អាយុ ៣២ឆ្នាំ ជានីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករ ទីកន្លែងកំណើត[redacted] ខេត្តបន្ទាយមានជ័យ អាសយដ្ឋានបច្ចុប្បន្នភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] ពន "រស់" ម្តាយឈ្មោះ [redacted] អៀត "រស់" កម្រិតវប្បធម៌ថ្នាក់ទី៥ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

**កំណត់ដាក់ពន្ធនាគាររយៈពេល ៤ (បួន) ខែ តែទោសនេះអនុវត្តក្នុងពន្ធនាគារពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ ទោសនៅសល់ព្យួរធម្មតា** តាមបញ្ញត្តិមាត្រា ១០៤ ដល់មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិចំការគ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ



Scanned with CamScanner

កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**១.៤.** ឈ្មោះ [redacted] **មិនា** ភេទប្រុស កើតឆ្នាំ១៩៩១ ជានីតិជន សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរជាសន្តិសុខ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពង់ធំ អាសយដ្ឋានបច្ចុប្បន្ន នៅភូមិចំការគេ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] អាន "រស់" ម្តាយឈ្មោះ [redacted] ម៉ុំ "រស់" កម្រិតវប្បធម៌ថ្នាក់ទី៣ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ *(ក្រៅឃុំ)*

**កំណត់ដាក់ពន្ធនាគាររយៈពេល ៤ (បួន) ខែ តែទោសនេះអនុវត្តក្នុងពន្ធនាគារ ពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ ទោសនៅសល់ព្យួរធម្មតា** តាមបញ្ញត្តិមាត្រា ១០៤ ដល់មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិចំការគេ ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២. អំពីវត្ថុចាប់យក**

**២.១. រឹបអូសវត្ថុចាប់យកមាន** ដំពាមកៅស៊ូ ចំនួន ០១ និងគ្រាប់ឃ្លីដែក ចំនួន ០១ គ្រាប់ ដកហូតពីឈ្មោះ គីម តុលា។

**២.២. ប្រគល់វត្ថុចាប់យកឱ្យម្ចាស់ដើមវិញមាន**

- នាឡិកាដៃ ចំនួន ០២គ្រឿង
- កាស Bluetooth (apple) ចំនួន ០១។
- ទូរស័ព្ទ ចំនួន ០២គ្រឿង ម៉ាក Vivo v2026 ពណ៌ខ្មៅ IMEI1: 865091059208176 និងម៉ាក Vivo 1906 ពណ៌ខ្មៅលាយក្រហម IMEI1: 864809045390654។

*"វត្ថុចាប់យកនេះត្រូវបានរក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាល នៃសាលាដំបូងខេត្តបន្ទាយមានជ័យ តាមកំណត់ហេតុទទួលវត្ថុតាង លេខ ១៥៤ អ.យ.ខ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។"*

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **តុលា** ភេទប្រុស, ឈ្មោះ [redacted] **មិនា** ភេទប្រុស, ឈ្មោះ [redacted] **ចិន** ភេទប្រុស និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **វណ្ណា** ភេទប្រុស។

*ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៣កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

បន្ទាយមានជ័យ, ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner